**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងការបរទេស**
**និងសហប្រតិបត្តិការអន្តរជាតិ**

# សេចក្តីប្រកាសព័ត៌មាន

## លទ្ធផលនៃទស្សនកិច្ចផ្លូវការរបស់ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី ប្រាក់ សុខុន រដ្ឋមន្ត្រីការបរទេស និងសហប្រតិបត្តិការអន្តរជាតិ នៃព្រះរាជាណាចក្រកម្ពុជា នៅសាធារណរដ្ឋកូរ៉េ

**(ថ្ងៃទី០៦-០៨ ខែកញ្ញា ឆ្នាំ២០២១)**

-------

តបតាមការអញ្ជើញរបស់**ឯកឧត្តម ចុង អ៊ើយយ៉ុង** រដ្ឋមន្ត្រីការបរទេស នៃសាធារណរដ្ឋកូរ៉េ **ឯកឧត្តម ប្រាក់ សុខុន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីការបរទេស និងសហប្រតិបត្តិការអន្តរជាតិ នៃព្រះរាជាណាចក្រកម្ពុជា បានអញ្ជើញទៅបំពេញទស្សនកិច្ចផ្លូវការនៅសាធារណរដ្ឋកូរ៉េ ពីថ្ងៃទី០៦ ដល់០៨ ខែកញ្ញា ឆ្នាំ ២០២១។ ក្នុងអំឡុងពេលទស្សនកិច្ចនេះ រដ្ឋមន្ត្រីទាំងពីរបានជួបពិភាក្សាទ្វេភាគី និងធ្វើជាសហប្រធាន នៃកិច្ចប្រជុំរដ្ឋមន្ត្រីការបរទេសមេគង្គ-សាធារណរដ្ឋកូរ៉េលើកទី ១១ ។

**១. <u>កិច្ចប្រជុំទ្វេភាគី</u>**

ក្នុងកិច្ចប្រជុំទ្វេភាគីនៅព្រឹកថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ២០២១ **ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី** និង**ឯកឧត្តម ចុង អ៊ើយយ៉ុង** បានកត់សម្គាល់ដោយការពេញចិត្តយ៉ាងខ្លាំងចំពោះការបន្តរីកចម្រើននៃទំនាក់ទំនងទ្វេភាគី និងកិច្ចសហប្រតិបត្តិការលើគ្រប់វិស័យរវាងប្រទេសទាំងពីរ ទាំងក្នុងក្របខ័ណ្ឌទ្វេភាគី និងពហុភាគី ដែលឆ្លុះបញ្ចាំងតាមរយៈការផ្លាស់ប្តូរទស្សនកិច្ចជាន់ខ្ពស់ជាញឹកញាប់រវាងប្រទេសទាំងពីរ។

ស្របពេលដែលព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋកូរ៉េ នឹងប្រារព្ធខួបលើកទី ២៥ នៃការបង្កើតទំនាក់ទំនងការទូតឡើងវិញ នៅឆ្នាំក្រោយនេះ រដ្ឋមន្ត្រីការបរទេសទាំងពីរបានបញ្ជាក់សាជាថ្មីពីការប្តេជ្ញាចិត្តក្នុងការពង្រឹង និងពង្រីកទំនាក់ទំនងទ្វេភាគី ដ៏ល្អដែលមានស្រាប់បន្ថែមទៀត ដើម្បីជាប្រយោជន៍រួម នៃប្រជាជាតិទាំងពីរ និងសម្រាប់សន្តិភាព សន្តិសុខ ស្ថិរភាព និងវិបុលភាពក្នុងតំបន់ និងសកលលោក។ ក្នុងន័យនេះ រដ្ឋមន្ត្រីទាំងពីរបានពិភាក្សាពីមធ្យោបាយ និងវិធីសាស្ត្រក្នុងការធ្វើឱ្យកាន់តែស៊ីជម្រៅនូវកិច្ច

អាសយដ្ឋាន: លេខ ៣ វិថី សម្តេច ហ៊ុន សែន
សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា



ទូរស័ព្ទ : (855) 23 216 122
ទូរសារ : (855) 23 216 141, 023 213 341
អ៊ីម៉ែល : mfaic@mfaic.gov.kh

សហប្រតិបត្តិការក្នុងវិស័យយោធា ពាណិជ្ជកម្ម ការវិនិយោគ កសិកម្ម ការងារ សុខាភិបាល បច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន វិទ្យាសាស្ត្រនិងនវានុវត្តន៍ ទេសចរណ៍ ការអប់រំ និងបរិស្ថាន។

រដ្ឋមន្ត្រីទាំងពីរក៏មានការពេញចិត្ត ដោយបានកត់សម្គាល់ពីស្ថិរភាព នៃទំហំពាណិជ្ជកម្មទ្វេភាគីរវាងប្រទេសទាំងពីរ និងកំណើននៃការវិនិយោគរបស់សាធារណរដ្ឋកូរ៉េនៅកម្ពុជា ទោះបីជាមានការរីករាលដាលនៃជំងឺកូវីដ-១៩ ក៏ដោយ។ រដ្ឋមន្ត្រីទាំងពីរក៏មានសុទិដ្ឋិនិយមថា កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីកម្ពុជា-សាធារណកូរ៉េ (CKFTA) ដែលនឹងត្រូវចុះហត្ថលេខានៅដើមខែតុលាខាងមុខនេះ នឹងជួយជំរុញពាណិជ្ជកម្ម និងការវិនិយោគទ្វេភាគីបន្ថែមទៀត ព្រមទាំងជួយពន្លឿនការស្តារសេដ្ឋកិច្ច នៃប្រទេសទាំងពីរឡើងវិញ នៅក្រោយវិបត្តិកូវីដ-១៩ ។

**ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី** បានថ្លែងអំណរគុណដល់រដ្ឋាភិបាលសាធារណរដ្ឋកូរ៉េ ក្នុងការផ្តល់ជំនួយអភិវឌ្ឍន៍ដល់ប្រទេសកម្ពុជា ដែលបានរួមចំណែកយ៉ាងសំខាន់ដល់ការអភិវឌ្ឍសេដ្ឋកិច្ច-សង្គមកម្ពុជា។ ឯកឧត្តមបានសង្កត់ធ្ងន់ថា កម្ពុជាស្ទប់ស្ទែងចំពោះកិច្ចខិតខំប្រឹងប្រែងរបស់សាធារណរដ្ឋកូរ៉េក្នុងការពង្រីកជំនួយអភិវឌ្ឍន៍ក្រោមគោលនយោបាយឆ្ពោះទៅរកទិសខាងត្បូងថ្មី និងស្វាគមន៍**គោលនយោបាយឆ្ពោះទៅរកទិសខាងត្បូងថ្មីបូក** ដែលផ្តោតលើវិស័យសំខាន់ៗចំនួន ៧ ក្នុងនោះរួមមានកិច្ចសហប្រតិបត្តិការគ្រប់ជ្រុងជ្រោយលើវិស័យសុខាភិបាល និងវេជ្ជសាស្ត្រ។

**ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី** បានកោតសរសើររដ្ឋាភិបាល និងប្រជាជនកូរ៉េ ចំពោះការទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីដ-១៩ ប្រកបដោយប្រសិទ្ធភាព ដែលធ្វើឱ្យការស្តារសេដ្ឋកិច្ច-សង្គមមានសន្ទុះខ្លាំង និងបានវាយតំលៃខ្ពស់ ចំពោះតួនាទីដ៏សកម្មរបស់សាធារណរដ្ឋកូរ៉េ ក្នុងក្របខ័ណ្ឌវ៉ាក់សាំងពហុភាគីនិយម។ ឯកឧត្តមក៏បានសំដែងនូវអំណរអរគុណរបស់កម្ពុជាចំពោះរដ្ឋាភិបាលសាធារណរដ្ឋកូរ៉េ ដែលបានបរិច្ចាគ និងផ្គត់ផ្គង់សម្ភារៈវេជ្ជសាស្ត្រដល់កម្ពុជា ដើម្បីប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ-១៩។ រដ្ឋមន្ត្រីការបរទេសសាធារណរដ្ឋកូរ៉េបានកោតសរសើររាជរដ្ឋាភិបាលកម្ពុជាក្នុងការដាក់ចេញវិធានការប្រកបដោយប្រសិទ្ធភាព ដើម្បីប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ-១៩ រួមជាមួយយុទ្ធនាការចាក់វ៉ាក់សាំងទាន់ពេលវេលា នៅទូទាំងប្រទេស។ ឯកឧត្តមក៏បានវាយតម្លៃខ្ពស់ចំពោះកម្ពុជា ដែលបានផ្តល់ជំនួយដ៏សប្បុរសដល់ប្រទេសជិតខាង ដើម្បីជួយប្រទេសទាំងនោះប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ-១៩ ។

**ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** បានសម្តែងនូវអំណរអរគុណដោយស្មោះចំពោះរដ្ឋាភិបាលកូរ៉េដែលបានយកចិត្តទុកដាក់ខ្ពស់ដល់សហគមន៍ខ្មែរនៅកូរ៉េ។ ជាការឆ្លើយតប **ឯកឧត្តម ឌុង អើយយ៉ុង** បានថ្លែងអំណរគុណដល់សហគមន៍ខ្មែរនៅកូរ៉េ ដែលបានរួមចំណែកយ៉ាងវិជ្ជមានដល់ការអភិវឌ្ឍសេដ្ឋកិច្ច និងការធ្វើពិពិធកម្មវប្បធម៌របស់កូរ៉េ។ សាធារណរដ្ឋកូរ៉េបានសន្យាថានឹងបង្កើនចំនួនកូតាពលករកម្ពុជា និងចំនួនអាហារូបករណ៍ដល់កម្ពុជា នាពេលអនាគត។

**ឯកឧត្តម ឌុង អើយយ៉ុង** បានបញ្ជាក់សារជាថ្មីថា ដោយសារកម្ពុជាជាប្រទេសមួយក្នុងចំណោមប្រទេសដៃគូអាទិភាព ក្នុងកម្មវិធីជំនួយអភិវឌ្ឍន៍ផ្លូវការ និងជាដៃគូស្នូលក្នុងគោលនយោបាយឆ្ពោះទៅរក

ទិសខាងត្បូងថ្មីរបស់សាធារណរដ្ឋកូរ៉េ សាធារណរដ្ឋកូរ៉េនឹងបន្តជួយ និងសហការជាមួយកម្ពុជា ក្នុងវិស័យគ្រប់គ្រងទឹក សុខភាពសាធារណៈ ការដឹកជញ្ជូន ការអប់រំ និងវិស័យចាំបាច់ផ្សេងទៀតនៅកម្ពុជា។

**ឯកឧត្តម រដ្ឋមន្ត្រីការបរទេសសាធារណរដ្ឋកូរ៉េ** បានកោតសរសើរចំពោះតួនាទីដ៏សកម្មរបស់កម្ពុជាក្នុងកិច្ចប្រតិបត្តិការរក្សាសន្តិភាពក្រោមឆ័ត្រអង្គការសហប្រជាជាតិ នៅទ្វីបអាហ្វ្រិក និងមជ្ឈិមបូព៌ា ដែលបានរួមចំណែកដល់សន្តិភាព និងស្ថិរភាពក្នុងតំបន់ទាំងនោះ ហើយក៏បានថ្លែងអំណរគុណកម្ពុជាចំពោះតួនាទីយ៉ាងសកម្ម ក្នុងការសម្របសម្រួលទំនាក់ទំនងក្នុងក្របខណ្ឌដៃគូសន្ទនាអាស៊ាន-សាធារណរដ្ឋកូរ៉េ និងកិច្ចសហប្រតិបត្តិការមេគង្គ-សាធារណរដ្ឋកូរ៉េ។

ក្នុងការដោះស្រាយបញ្ហាប្រឈម នៃបម្រែបម្រួលអាកាសធាតុ **ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី** បានអបអរសាទរសាធារណរដ្ឋកូរ៉េ ដែលទទួលបានភាពជោគជ័យក្នុងការធ្វើជាម្ចាស់ផ្ទះកិច្ចប្រជុំកំពូលលើកទី ២ ស្តីពីភាពជាដៃគូដើម្បីការអភិវឌ្ឍបៃតង និងគោលដៅពិភពលោកឆ្នាំ២០៣០ កាលពីខែឧសភា កន្លងទៅ និងគាំទ្រយ៉ាងមុតមាំ ចំពោះគោលនយោបាយបៃតងថ្មី និងការប្តេជ្ញាចិត្តរបស់រដ្ឋាភិបាលកូរ៉េស្តីពីអព្យាក្រឹតភាពកាបូនឆ្នាំ ២០៥០។ **រដ្ឋមន្ត្រីការបរទេសសាធារណរដ្ឋកូរ៉េ** បានសម្តែងនូវការកោតសរសើរចំពោះ **សម្តេចតេជោនាយករដ្ឋមន្ត្រី ហ៊ុន សែន** ដែលបានរួមចំណែកដល់ភាពជោគជ័យ នៃកិច្ចប្រជុំកំពូលខាងលើ ដោយក្នុងពេលនោះ **សម្តេចតេជោនាយករដ្ឋមន្ត្រី** ក៏បានសង្កត់ធ្ងន់ពីតម្រូវការ នៃការអភិវឌ្ឍបច្ចេកវិទ្យាបៃតង។

**ឯកឧត្តម ឈុង អឺយយ៉ុង** បានបញ្ជាក់ជាថ្មីពីការគាំទ្រយ៉ាងពេញទំហឹងរបស់សាធារណរដ្ឋកូរ៉េ ដល់កម្ពុជាក្នុងការធ្វើជាម្ចាស់ផ្ទះកិច្ចប្រជុំកំពូលអាស៊ី-អឺរ៉ុប លើកទី ១៣ នៅខែ វិច្ឆិកា ឆ្នាំ ២០២១ និងការទទួលតំណែងជាប្រធានអាស៊ាននៅឆ្នាំក្រោយ ។

ក្នុងពេលអាហារថ្ងៃត្រង់រៀបចំដោយ**ឯកឧត្តម ឈុង អឺយយ៉ុង** រដ្ឋមន្ត្រីទាំងពីរក៏បានផ្លាស់ប្តូរទស្សនៈគ្នាលើបញ្ហាតំបន់ និងអន្តរជាតិ ដែលជាកង្វល់រួម។

## ២. <u>កិច្ចប្រជុំរដ្ឋមន្ត្រីការបរទេសមេគ្គង-សាធារណរដ្ឋកូរ៉េលើកទី ១១</u>

នៅរសៀលថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ២០២១ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ប្រាក់ សុខុន** រដ្ឋមន្ត្រីការបរទេស និងសហប្រតិបត្តិការអន្តរជាតិ បានអញ្ជើញចូលរួមដឹកនាំកិច្ចប្រជុំរដ្ឋមន្ត្រីការបរទេសមេគង្គ-សាធារណរដ្ឋកូរ៉េលើកទី១១ ជាមួយ **ឯកឧត្តម ឈុង អឺយយ៉ុង** រដ្ឋមន្ត្រីការបរទេសនៃសាធារណរដ្ឋកូរ៉េនៅទីក្រុងសេអ៊ូល។ កិច្ចប្រជុំនេះក៏មានការអញ្ជើញចូលរួមតាមប្រព័ន្ធវីដេអូ ពីបណ្តាប្រទេសមេគង្គផ្សេងទៀត រួមមាន ឡាវ មីយ៉ាន់ម៉ា ថៃ និងវៀតណាម ។

រដ្ឋមន្ត្រីការបរទេសមេគង្គ-សាធារណរដ្ឋកូរ៉េ បានពិនិត្យឡើងវិញនូវវឌ្ឍនភាព ដែលមានកន្លងមកនៃកិច្ចសហប្រតិបត្តិការមេគង្គ-សាធារណរដ្ឋកូរ៉េ ផ្អែកលើសសរស្តម្ភទាំង៣ ដែលរួមមានប្រជាជន វិបុលភាព និងសន្តិភាព ព្រមទាំងវិស័យអាទិភាពទាំង៧ នៃសេចក្តីថ្លែងការណ៍ទន្លេមេគង្គ-ទន្លេហាន៖ (i) វប្បធម៌ និងទេសចរណ៍ (ii) ការអភិវឌ្ឍធនធានមនុស្ស (iii) កសិកម្ម និងអភិវឌ្ឍន៍ជនបទ (iv) ហេដ្ឋារចនាសម្ព័ន្ធ (v) បច្ចេកវិទ្យាព័ត៌មាន និងទូរគមនាគមន៍ (ICT) (vi) បរិស្ថាន និង (vii) បញ្ហា

ប្រឈមផ្នែកសន្តិសុខមិនមែនប្រពៃណី។ រដ្ឋមន្ត្រីទាំងអស់បានបន្តការប្ដេជ្ញាចិត្តក្នុងការសម្របសម្រួលបន្ថែមទៀតនូវការដាក់ឲ្យប្រើប្រាស់យ៉ាងទូលំទូលាយនៃបច្ចេកវិទ្យាព័ត៌មាន និងទូរគមនាគមន៍ ក្នុងកិច្ចការអភិបាលកិច្ច ការពង្រឹងកិច្ចសហប្រតិបត្តិការ ការចូលរួមរបស់វិស័យឯកជន និងការជំរុញការវិនិយោគបន្ថែមទៀតនៅក្នុងវិស័យឧស្សាហកម្ម និងការផ្លាស់ប្តូរផ្នែកឌីជីថល នាពេលអនាគត នៅក្នុងអនុតំបន់មេគង្គ ពិសេសនៅក្នុងវិស័យសេដ្ឋកិច្ចបែបឌីជីថល ប្រកចេញ-ចូលជាតិតែមួយ ពាណិជ្ជកម្ម អេឡិចត្រូនិក សន្តិសុខតាមប្រព័ន្ធអ៊ីនធឺណែត បណ្ដាញប្រព័ន្ធ 5G ដែលធានាបាននូវសុវត្ថិភាព បញ្ញាសិប្បនិម្មិត និងទិន្នន័យធំ ដោយគិតគូរពិចារណាទៅលើជំងឺរាតត្បាតកូវីដ-១៩ និងបញ្ហាប្រឈមថ្មីៗនានាដែលកំពុងតែកើតមាន។

អង្គប្រជុំបានឯកភាពពន្យារ «ឆ្នាំផ្លាស់ប្តូរមេគង្គ-សាធារណរដ្ឋកូរ៉េ» ដល់ឆ្នាំ២០២២ ដើម្បីជំរុញឲ្យកាន់តែស៊ីជម្រៅនូវការផ្លាស់ប្តូរវប្បធម៌ និងការយល់ដឹងគ្នាទៅវិញទៅមក តាមរយៈការរៀបចំព្រឹត្តិការណ៍ផ្សេងៗក្នុងចំណោមប្រទេសទាំង៦ ដោយរង់ចាំការអនុម័តពីប្រមុខដឹកនាំមេគង្គ-សាធារណរដ្ឋកូរ៉េ ក្នុងកិច្ចប្រជុំកំពូលមេគង្គ-កូរ៉េលើកទី៣។ លើសពីនេះ រដ្ឋមន្ត្រីនៃបណ្ដាប្រទេសមេគង្គ-សាធារណរដ្ឋកូរ៉េ បានស្វាគមន៍ដោយក្ដីសង្ឃឹមខ្ពស់ចំពោះវេទិកាធុរកិច្ចមេគង្គ-សាធារណរដ្ឋកូរ៉េលើកទី ៩ ដែលនឹងត្រូវរៀបចំឡើងនៅប្រទេសកម្ពុជា នាអំឡុងពេលចុងឆ្នាំនេះ។

ឆ្លៀតក្នុងឱកាសនេះ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** បានលើកឡើងពីតួនាទីសំខាន់នៃក្របខ័ណ្ឌកិច្ចសហប្រតិបត្តិការមេគង្គ-សាធារណរដ្ឋកូរ៉េ និងគោលនយោបាយឆ្ពោះទៅភាគខាងត្បូងបូកថ្មី ក្នុងការថែរក្សាសន្តិភាព និងស្ថិរភាពនៅក្នុងអនុតំបន់មេគង្គ។ តាមរយៈការប្ដេជ្ញាចិត្តរួមគ្នាដើម្បីប្រយុទ្ធប្រឆាំងនឹងជំងឺរាតត្បាតកូវីដ-១៩ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** បានគូសបញ្ជាក់អំពីតម្រូវក្នុងការពន្លឿននូវដំណើរការចាក់វ៉ាក់សាំង ដោយប្រកាន់ភ្ជាប់គោលការណ៍បរិយាប័ន្ន និងមិនមានការរើសអើង។ ចំពោះការស្ដារឡើងវិញនៃសេដ្ឋកិច្ចដំណាក់កាលដំបូងក្នុងអំឡុងពេលនៃជំងឺរាតត្បាតកូវីដ-១៩ ឯកឧត្តមបានលើកឡើងបន្ថែមទៀតថា ប្រទេសសមាជិកទាំងអស់ត្រូវរៀបចំផែនការធ្វើដំណើរប្រកបដោយសុវត្ថិភាពតាមរយៈការទទួលស្គាល់នូវប័ណ្ណចាក់វ៉ាក់សាំង បញ្ជរត្រួតពិនិត្យ និងធ្វើតេស្ត PCR ប្រកបដោយប្រសិទ្ធភាពនៅតាមព្រលានយន្តហោះ និងច្រកព្រំដែនទាំងអស់ និងប្រព័ន្ធតាមដាននិងត្រួតពិនិត្យបណ្ដាញជំងឺកូវីដ-១៩។

**ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** ក៏បានសង្កត់ធ្ងន់ថា ប្រទេសមេគង្គ និងសាធារណរដ្ឋកូរ៉េ គួរត្រៀមនូវផែនការស្ដារឡើងវិញក្រោយវិបត្តិជំងឺរាតត្បាតថ្នាក់តំបន់ដោយប្រុងប្រយ័ត្ន ដើម្បីធានាឱ្យបាននូវភាពធន់ និងនិរន្តរភាពនៃសេដ្ឋកិច្ចក្នុងតំបន់ តាមរយៈកិច្ចសហប្រតិបត្តិការកាន់តែរឹងមាំរវាងរដ្ឋនិងឯកជន ការពង្រឹងសមត្ថភាពសហគ្រាសខ្នាតមីក្រូ តូច និងមធ្យម (MSMEs) ការលើកកម្ពស់ការតភ្ជាប់ផ្នែកទន់និងរឹងដើម្បីសម្របសម្រួលពាណិជ្ជកម្មនិងការវិនិយោគ ថាមពលបៃតង និងការផ្លាស់ប្តូរផ្នែកឌីជីថល នៅក្នុងអនុតំបន់មេគង្គ។

នៅចុងបញ្ចប់នៃកិច្ចប្រជុំ រដ្ឋមន្ត្រីទាំងអស់បានអនុម័តលើសេចក្តីប្រកាសសហប្រធាននៃកិច្ចប្រជុំរដ្ឋមន្ត្រីការបរទេសមេគង្គ-សាធារណរដ្ឋកូរ៉េលើកទី១១ និងបានអនុម័តការអនុវត្តគម្រោងចំនួន ៧ សម្រាប់

ឆ្នាំ២០២១ ក្រោមមូលនិធិកិច្ចសហប្រតិបត្តិការមេគង្គ-សាធារណរដ្ឋកូរ៉េជុំទី៥ ទៅដល់បណ្តាប្រទេសមេគង្គ សាធារណរដ្ឋកូរ៉េ និងវិទ្យាស្ថានមេគង្គ (MI)។

កិច្ចប្រជុំនេះត្រូវបានបញ្ចប់ប្រកបដោយផ្លែផ្កាគួរជាទីមោទក តាមរយៈការយល់ឃើញរួមគ្នាលើបញ្ហាតំបន់ និងអន្តរជាតិនានា ជាពិសេសកិច្ចខិតខំប្រឹងប្រែងរួមគ្នាក្នុងការប្រយុទ្ធប្រឆាំងនឹងជំងឺរាតត្បាតកូវីដ-១៩ និងការប្តេជ្ញាចិត្តក្នុងការកសាងភាពធន់សម្រាប់សេដ្ឋកិច្ចក្នុងតំបន់។

៣. <u>ការជួបសំណេះសំណាលជាមួយសហគមន៍ខ្មែរនៅសាធារណរដ្ឋកូរ៉េ</u>

ឆ្លៀតក្នុងឱកាសទស្សនកិច្ចនេះ នៅថ្ងៃទី០៧ ខែ កញ្ញា ឆ្នាំ ២០២១ **ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី** បានជួបសំណេះសំណាលជាមួយសហគមន៍ខ្មែរ នៅសាធារណរដ្ឋកូរ៉េ តាមប្រព័ន្ធវីដេអូ និងបានពាំនាំការសួរសុខទុក្ខពីសំណាក់ **សម្តេចតេជោនាយករដ្ឋមន្ត្រី** ជូនពួកគាត់ផងដែរ។ **ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី** ក៏បានលើកទឹកចិត្តដល់បងប្អូនខ្មែរ ឱ្យខិតខំប្រឹងប្រែងធ្វើការ និងរៀនសូត្រ ដើម្បីទទួលបានចំណេះដឹង និងចំណេះធ្វើទៅលើកស្ទួយជីវភាពគ្រួសារ និងជួយអភិវឌ្ឍប្រទេសជាតិ។ ជាមួយគ្នានេះ **ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី** ក៏បានណែនាំឱ្យពួកគាត់ថែទាំសុខភាពឱ្យបានល្អ និងបន្តគោរពវិធានការសុខាភិបាលរបស់អាជ្ញាធរកូរ៉េឱ្យបានខ្ជាប់ខ្ជួនក្នុងកាលៈទេសៈ នៃជំងឺកូវីដ-១៩ ដ៏លំបាកនេះ៕

ថ្ងៃព្រហស្បតិ៍ ៣ កើត ខែភទ្របទ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០២១